# អត្រាកំនែ ប្រវត្តិវិទ្យា ថ្នាក់ទី១២
# ប្រលងឆមាសលើកទី១ សម័យប្រលង ១៤ មិនា ២០០២

## ខែមច័ន្ទសុក្រិត

I. បំពេញល្បះ:

១). សម្ដេចនរោត្ដមសីហនុបានឡើងសោយរាជ្យលើកទី១ នៅឆ្នាំ ១៩៤១ ។

២). កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្ដីពីបញ្ហាសន្តិភាពនៅប្រទេសកម្ពុជាត្រូវបានចុះហត្ថលេខានៅថ្ងៃ ២៣ ខែ តុលា ឆ្នាំ ១៩៩១ ។

៣). សង្គ្រាមឥណ្ឌូចិន ១៩៧០-១៩៧៥ ត្រូវបានបញ្ចប់នៅក្នុងអណត្តិប្រធានាធិបតីសហរដ្ឋអាមេរិចឈ្មោះ កាទ័រ ។

៤). លោក វីនស្ដុន ឆឺឈីល នាយករដ្ឋមន្ត្រីអង់គ្លេសជាសមាជិកនៃគណបក្ស អភិរក្សនិយម ។

៥). យានអវកាសទី១ របស់មនុស្សជាតិបានបង្ហោះទៅកាន់ទីអវកាសនៅឆ្នាំ ១៩៥៧ ។

II. ប្រទេសអ៊ីស្រាអែលយល់ព្រមប្រគល់តំបន់ ស៊ីណាអ៊ី ឲ្យប្រទេសអេស៊ីបវិញព្រោះ

- កិច្ចចរចារសន្តិភាពរវាងប្រទេសអេស៊ីប និងអ៊ីស្រាអែល (សាដាត និង បេគីន)។
- កិច្ចព្រមព្រៀងសន្តិភាព កំដាវីដ ឆ្នាំ ១៩៧៨។

III. ចលនាសង្គមរាស្ត្រនិយមជាចលនាបង្រួបបង្រួមជាតិ (និន្នាការៈ ស្ដាំនិយម រាជានិយម ឆ្វេងនិយម)។

ចលនានេះមានគោលបំណងស្ថាបនាប្រទេសកម្ពុជាទៅតាមលទ្ធិសង្គមនិយមព្រះពុទ្ធសាសនាខ្មែរ។

IV. វិស័យឧស្សាហកម្មនៅកម្ពុជានាសម័យសង្គមរាស្ត្រនិយមមានការរីកចម្រើនយ៉ាងខ្លាំងក្រោមការជួយជម្រុញរបស់សម្ដេច នរោត្ដម សីហនុ។ រោងចក្រដែលនៅសម័យនោះរួមមាន:

- រោងចក្រក្រដាស នៅឆ្លូង ខេត្តក្រចេះ
- រោងចក្រក្តារបន្ទះ នៅដីឥដ្ឋ ខេត្តកណ្ដាល
- រោងចក្រស្ករស នៅកំពង់ត្រាំ ខេត្តកំពង់ស្ពឺ
- រោងចក្រចម្រាញ់ប្រេងកាត នៅក្រុងព្រះសីហនុ
- រោងចក្រដំឡើងត្រាក់ទ័រ នៅក្រុងព្រះសីហនុ
- រោងចក្រកែវ នៅខេត្តកណ្ដាល
- រោងចក្រវាយភណ្ឌ នៅខេត្តកំពង់ចាម
- រោងចក្រស៊ីម៉ង់ នៅចក្រីទីង ខេត្តកំពត
- រោងចក្របាវក្រចៅ នៅដូនទាវ ខេត្តបាត់ដំបង
- រោងចក្រស្រាបៀរ នៅក្រុងព្រះសីហនុ
- រោងចក្រកៅស៊ូតង់ នៅខេត្តកណ្ដាល។

V. បារាំងយល់ប្រគល់ឯករាជ្យឲ្យប្រទេសកម្ពុជាព្រោះ

- ភាពទន់ខ្សោយរបស់មហាអំណាចអាណានិគមបារាំងនៅក្រោយសង្គ្រាមលោកលើកទី២
- ចលនារំដោះជាតិមាននៅ ទ្វីបអាស៊ី អាហ្វ្រិក និងអាមេរិចឡាទីន (ចលនារបស់ប្រជាជនកម្ពុជា)
- ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិដែលគាំទ្រដោយសហរដ្ឋអាមេរិច និងសហភាពសូវៀតប្រឆាំងនឹងនយោបាយអាណានិគម
- ព្រះបូជនីយកិច្ចទាមទារឯករាជ្យដឹកនាំដោយសម្តេចនរោត្តមសីហនុ
  + ព្រះរាជសកម្មភាពនៅប្រទេសបារាំង
  + ព្រះរាជសកម្មភាពនៅអាមេរិចខាងជើង
  + ព្រះរាជសកម្មភាពនៅតំបន់ស្វយ័ត

---


រៀបរៀង និងវាយអត្ថបទដោយៈ ខែម ច័ន្ទសុក្រិត
ឯកសារយោងៈ សៀវភៅថ្នាក់ទី១២ ចាស់+ថ្មី របស់ក្រសួងអប់រំ
អាប់ឡូតដោយៈ www.vinheasa.wordpress.com
លេខទូរស័ព្ទៈ ០៨៨ ៥៩ ០០០ ២០

អរគុណសម្រាប់ការទស្សនាប្លុករបស់ខ្ញុំ!!
សូមជួយកែតម្រូវផងបើមានកំហុសលើផ្នែកណាមួយនៃអត្ថបទ។